ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ: ០៦៧/២៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ សុក្រ ២ កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩*

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៦*

# សេចក្តីជូនដំណឹង

## អំពី

## សេចក្តីសម្រេចលើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ បុរី វិមានសំណាង ម.ក

ផ្សារមូលបត្រកម្ពុជា (ផមក) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនថា ផមក បានសម្រេចឯកភាពជាគោលការណ៍ លើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ នៅទីផ្សារគោលរបស់ បុរី វិមានសំណាង ម.ក នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦។ ដើម្បីអាចចុះបញ្ជី និងជួញដូរជាផ្លូវការនៅ ផមក បុរី វិមានសំណាង ម.ក ត្រូវតែទទួលបានការអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពី និយ័តករមូលបត្រកម្ពុជា (ន.ម.ក) និងត្រូវបំពេញនូវលក្ខខណ្ឌផ្សេងៗមួយចំនួនទៀតពាក់ព័ន្ធនឹងការចុះបញ្ជីនៅ ផមក។

សូមបញ្ជាក់ថា បុរី វិមានសំណាង ម.ក ជាក្រុមហ៊ុនទីមួយ ដែលទទួលបានការឯកភាពជាគោលការណ៍ លើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ នៅទីផ្សារគោល សម្រាប់ឆ្នាំ២០២៦នេះ។ គួរកត់សម្គាល់ផងដែរថា បុរី វិមានសំណាង ម.ក ជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យរបស់កម្ពុជា ដែលចូលរួមក្នុងការអភិវឌ្ឍន៍ និងលក់អចលនទ្រព្យបែបលំនៅដ្ឋាន និងពាណិជ្ជកម្ម។

ផ្សារមូលបត្រកម្ពុជា

Cambodia Securities Exchange

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង÷
នាយកដ្ឋានចុះបញ្ជី និងផ្តល់ព័ត៌មាន
អ៊ីម៉ែល÷ listing@csx.com.kh